# កិច្ចបាញ់សេកក្នុងពិធីលេងមេមត់នៅតំបន់កោះកេរ

នៅតំបន់កោះកេរ គេតែងប្រារព្ធពិធីលេងមេមត់ស្ទើរតែជារៀងរាល់ឆ្នាំ តែពិធីនេះធ្វើឡើងក្នុងគោលបំណងលាបំណន់ ឬបំពេញតាមកិច្ចសន្យាដែលបានជំពាក់ជាមួយពពួកអមនុស្សតែប៉ុណ្ណោះ។ ពោល គឺបន្ទាប់ពីមានសមាជិកគ្រួសារណាម្នាក់មានជំងឺ គេតែងទៅរកអ្នកបេះបូល ឬទៅបញ្ជាន់រូបដើម្បីសួររកមូលហេតុនៃជំងឺជាក់ជាពុំខាន។ ប្រសិនអមនុស្សទាមទារឱ្យលេងមេមត់នោះគេនឹងត្រូវរៀបចំកិច្ចនេះចំនួន៣ឆ្នាំជាប់ៗគ្នា នៅរដូវផ្កាចាររីកក្នុងខែមាឃ ដែលគេច្រើនហៅថា "**ខែមាឃផ្កាចារ**"។ ពិធីនេះ គេធ្វើនៅពេលយប់ដែលរួមបញ្ចូលដោយកិច្ចជាច្រើនដំណាក់កាល ដូចជា កិច្ចសែនគ្រូភ្លេង កិច្ចលេងអ្នកតា កិច្ចលេងមេមត់ កិច្ចបាញ់សេក និងកិច្ចកាច់ផ្កាសាពិតាន ជាដើម។ នៅក្នុងអត្ថបទខ្លីនេះ ខ្ញុំនឹងលើកនិងពិចារណាត្រឹមតែ "**កិច្ចបាញ់សេក**" មួយប៉ុណ្ណោះ ដោយយកករណីសិក្សានៅភូមិកោះកេរ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ។ តើហេតុអ្វីបានជាត្រូវបាញ់សេក? តើសេកតំណាងឱ្យអ្វី? ហេតុអ្វីបានជាត្រូវផ្តាច់រវាងភពមនុស្សនិងអមនុស្ស?

កិច្ចបាញ់សេក ជាកិច្ចមួយដែលប្រារព្ធនៅវេលាជិតភ្លឺ ហើយវត្តមានរបស់រូបតំណាងសត្វសេក គេឃើញនៅលើកំពូលនៃជមគុំសំណុំ ឬជមគុំសង្វារ។ លោក ព្រាន់ សុភារៈ យល់ថា ជមគុំសំណុំ ឬជមគុំសង្វារ សំដៅដល់ "ជមគ្រូកំណើត" ដែលមនុស្សគ្រប់រូបកើតមកតែងតែមានគ្រូកំណើតប្រចាំខ្លួន ហើយអ្នកនោះគឺជាគ្រូដើមដែលតាមថែរក្សាការពារពួកគេ។ ចំណែកឯ លោកសាស្ត្រាចារ្យ អាំង ជូលាន បង្ហាញថា ជមទាំងនោះមានសញ្ញាបញ្ជាក់ពីលក្ខណៈជាមនុស្សខ្លះដែរ ដ្បិតជួនកាលគេលម្អដោយមួកពណ៌ក្រហមរាងស្រួចចំកណ្តាល និងខ្លះទៀតមានក្រវាត់ចង្កេះទៀតផង។ គំនិតរបស់អ្នកស្រាវជ្រាវទាំងពីរនេះ គឺច្បាស់ណាស់ថា ជមនេះបង្ហាញអំពីលក្ខណៈសម្គាល់របស់មនុស្ស។ ជាក់ស្តែង ជមគុំសំណុំ បង្ហាញអំពីលក្ខណៈរបស់មនុស្សពេលកើតដែលមានស្រោមទឹកភ្លោះទាំងមូល។ សម្ភារៈដែលយកមកធ្វើជមទាំងនេះ មានដូចជាមើមកំភ្លឹង ឬផ្លែដូង ឬដើមស្នែងគង់ ឬដើមរលក ពោលគឺគេអាចរៀបចំខុសគ្នា អាស្រ័យទៅតាមការទាមទាររបស់អមនុស្ស ហើយនៅកន្ទង់មាននិមិត្តសញ្ញាបូក (រូបលេខ១)។ ជាទូទៅពេលមេមត់ (ខ្មោច) ចូលសណ្ឋិតក្នុងខ្លួន រូបស្នងតែងយកកន្សែងមកគ្របមុខ នោះគេនឹងដឹងច្បាស់ថាមេមត់នេះ ជាគុំសំណុំជាក់ជាមិនខាន (រូបលេខ២-៣)។ រីឯ ជមគុំសង្វារក៏ពុំខុសគ្នាប៉ុន្មានទេ ពោល គឺជាការបង្ហាញលក្ខណៈរបស់មនុស្សនៅពេលកើតមក ដែលតែងមានស្រោមទឹកភ្លោះបានបែក ហើយរុំ

ព័ទ្ធជុំវិញទារក។ ជមនេះជាទូទៅធ្វើអំពីឈើរាងស៊ីឡាំង ហើយកន្ទង់មាននិមិត្តសញ្ញាដក (រូបលេខ២)។ ពេលមេមត់ (ខ្មោច) ចូលសណ្ឋិត គឺភាគច្រើនរូបស្នងតែងយកកន្សែងមកបង់នឹងក (រូបលេខ៥)។ ម្ល៉ោះហើយ យើងអាចសន្និដ្ឋានបានថា ជមគុំសំណុំ និងជមគុំសង្វារ គឺជារូបតំណាងឱ្យលក្ខណៈ ឬអត្តសញ្ញាណផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ។

អ្វីដែលគួរយកមកពិចារណាមួយទៀតនោះ គឺសត្វសេកដែលនៅលើកំពូលនៃជម ថាតើតំណាងឱ្យអ្វី? (រូបលេខ៦)។ សត្វសេក គឺជាបក្សីដែលមានពណ៌ឆើតឆាយ និងអាស្រ័យផលរស់នៅក្នុងព្រៃ។ បើពិចារណាអំពីការប្រៀបធៀបរវាងវិស័យស្រុក (ភពមនុស្ស) និងវិស័យព្រៃ (ភពអមនុស្ស) បង្ហាញឱ្យឃើញថា សត្វសេកតំណាងឱ្យអមនុស្ស ដ្បិត សេក ជាសត្វរស់នៅក្នុងព្រៃ។ គំនិតនេះហាក់បីដូចជាស្របគ្នាទៅនឹងជំនឿរបស់ជនជាតិដើមភាគតិចកួយនៅភូមិវាលវែង ខេត្តកំពង់ធំ ដែលអ្នកស្រុកជឿថា សត្វសេក គឺតំណាងឱ្យដូនតារបស់ខ្លួន។ ជាក់ស្តែង ក្នុងអំឡុងពេលបុណ្យភ្ជុំបិណ្ឌ អ្នកស្រុក (ជនជាតិកួយ) តែងតែរៀបចំសែនព្រេន ដោយដាក់គ្រឿងសំណែនក្នុងច្រមនៅក្បែរដីស្រែ ហើយបើមានសត្វចាបឬសេកមកស៊ីសំណែននោះ គេចាត់ទុកថា ដូនតាបានមកទទួលផលហើយ។ ហេតុដូច្នេះ យើងអាចសន្និដ្ឋានបានថា ជមតំណាងឱ្យមនុស្ស រីឯសេកតំណាងឱ្យអមនុស្ស ពោលគឺអំឡុងពេលលេងមេមត់ តែងមានមនុស្ស និងអមនុស្សនៅជាមួយគ្នាបណ្តោះអាសន្ន តាមរយៈការសណ្ឋិតក្នុងខ្លួនរូបស្នង។ ដូច្នេះហើយ ទើបបានជាមានកិច្ចបាញ់សេកនេះឡើង ដែលគេប្រារព្ធឡើងដើម្បីផ្តាច់អមនុស្ស ឱ្យចេញពីមនុស្សបន្ទាប់ពីបញ្ចប់ពិធី ដ្បិតមនុស្ស និងអមនុស្សពុំអាចរស់ជាមួយគ្នាបានទេ (រូបលេខ៧-៨)។ ដោយឡែក ក្បាលគ្រាប់ដែលគេបាញ់នោះទៀតសោត គេធ្វើអំពីផ្លែត្របែក ដែលអាចពាក់ព័ន្ធនឹងការបែកចេញ ឬផ្តាច់ចេញៗ។ គំនិតនេះមានលក្ខណៈស្រដៀងគ្នានឹងពិធីលៀងអារក្សនៅភូមិសំបូរ ខេត្តកំពង់ធំ ដូច្នោះដែរ។ ពោល គឺនៅចុងបញ្ចប់នៃពិធី មានកិច្ចកាច់ផ្កាសាពិតាន ដែលនិយាយអំពីការបេះផ្កាត្របែក និងរៀបរាប់អំពីតួអង្គឈ្មោះ "អាគ្រោះ" បានទៅងូតទឹកក្បែរមាត់អណ្តូង ហើយរើសបានស្បែរបស់អ្នកពេង ព្រមទាំងទាមទារឱ្យអ្នកពេងត្រូវយកសំណងមកលោះយកស្បែនោះត្រឡប់ទៅវិញ។ បើពិចារណាលើសាច់រឿងនេះបន្តិច យើងឃើញថាតួអង្គ **"អាគ្រោះ"** គឺតំណាងឱ្យអមនុស្ស រីឯ **"អ្នកពេង"** គឺតំណាងឱ្យមនុស្ស។ ចំណែកឯ **"ស្បៃ"** គឺតំណាងឱ្យព្រលឹងរបស់អ្នកពេង ឬអ្នកចូលរូប ព្រោះស្បៃនោះគេបានរាប់ចំនួនរហូតដល់ទៅ "**ដប់ប្រាំបួន (១៩)**" ដែលគេដឹងច្បាស់ថា ជាចំនួនសរុបនៃព្រលឹងរបស់មនុស្ស។ ម្ល៉ោះហើយ ទើបគេត្រូវយករបស់ទៅលោះស្បៃ (ព្រលឹង) មកវិញ ដើម្បីកុំឱ្យមានការពាក់ព័ន្ធជាមួយអមនុស្សតទៅទៀត។

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង

## *អត្ថបទ៖ កិច្ចបាញ់សេកក្នុងពិធីលេងមេមត់នៅតំបន់កោះកេរ*

*សរុបមក "កិច្ចបាញ់សេក" ក្នុងពិធីលេងមេមត់នៅតំបន់កោះកេរ គឺជាពិធីបែបជីវចលមួយដែលឆ្លុះបញ្ចាំងពីជំនឿអរូបី និងការយល់ឃើញរបស់សហគមន៍មូលដ្ឋានចំពោះទំនាក់ទំនងរវាងមនុស្សនិងអមនុស្ស។ ជាក់ស្តែង តាមរយៈការប្រើប្រាស់ជមគុំសំណុំនិងជមគុំសង្វារ ដើម្បីតំណាងឱ្យអត្តសញ្ញាណរបស់មនុស្ស រួមផ្សំជាមួយនឹងរូបសេកដែលតំណាងឱ្យអមនុស្ស (ព្រលឹង ឬតួអង្គមកពីវិស័យព្រៃ) កិច្ចនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ចប់ទំនាក់ទំនងបណ្តោះអាសន្នដោយការបាញ់ផ្តាច់ដាច់ស្រេចនូវវត្តមានរបស់អមនុស្សឱ្យវិលត្រឡប់ទៅភពរបស់ខ្លួនវិញ។  គួរឱ្យកត់សម្គាល់នោះ ការប្រើប្រាស់ក្បាលគ្រាប់ធ្វើពីផ្លៃត្របែកក៏បង្កប់នូវអត្ថន័យនៃការកាត់ផ្តាច់ ឬបែកចេញពីគ្នាថែមទៀតផង។ ម្ល៉ោះហើយ កិច្ចនេះមិនត្រឹមតែបង្ហាញពីការដោះស្រាយបញ្ហាផ្លូវចិត្ត និងសុខភាពតាមរយៈជំនឿប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាកិច្ចការពារលំនឹងរវាងពិភពមនុស្ស និងពិភពអមនុស្ស ឱ្យរស់នៅឱ្យដាច់ចេញពីគ្នា។*

*អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង*

# បញ្ជីឯកសារពិគ្រោះ

ព្រាន់ សុភារៈ, ២០២៣ "ជំនឿលើគ្រូកំណើតនៅភូមិកោះកេរ", *អត្ថបទផ្សាយអនឡាញក្នុងគេហទំព័រ AMS Khmer Civilization*, ចុះផ្សាយនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ តាមរយៈតំណភ្ជាប់៖ https://khmercivilization.ams.com.kh/detail/27491

ព្រាប ចាន់ម៉ារ៉ា, "ក្បាច់លើស្លឹកត្នោត", អត្ថបទផ្សាយអនឡាញនៅក្នុង *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, ក្នុងជំពូក ៣៖ សិល្បៈ, អក្សរសាស្ត្រ ត្រង់មាតិកាទី៣៥, តាមរយៈតំណភ្ជាប់ https://www.yosothor.org/publications/khmer-renaissance/chapter-three/kbach-ler-slek-tnort.html

អាំង ជូលាន ២០០៦, "គ្រូកំណើត", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ ១, ភ្នំពេញ។

ANG Chouléan, 1986, *Les êtres surnaturels dans la religion*, Cedoreck, Paris.

## បទសម្ភាសន៍

១. លោក ហ៊ុន ហែល អាយុ ៦២ឆ្នាំ ជនជាតិដើមភាគតិចកួយនៅភូមិវាយវែង

២. លោក ជឹម ឡឿន អាយុ ៦៣ឆ្នាំ មេភូមិកោះកេរ និងជាមេក្មេងមេមត់ប្រចាំភូមិកោះកេរ

៣. លោកយាយ ម៉ាត់ អាយុ១០៥ឆ្នាំ រស់នៅភូមិកោះកេរ

៤. លោកយាយយោន អាយុ ៨៧ឆ្នាំ រស់នៅភូមិកោះកេរ។

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ១៖ ជមសំណុំ និងនិមិត្តសញ្ញាលេខបូក





រូបលេខ២-៣៖ យកកន្សែងគ្របមុខ នៅពេលមេមត់ចូលសណ្ឋិតក្នុងខ្លួនរូបស្នង

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ២៨៖ ជមគុំសង្វារ និងនិមិត្តសញ្ញាដក

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ៥៖ យកកន្ទេលបង់ក ពេលមេមត់ចូលសណ្ឋិតក្នុងខ្លួនរូបស្នង



រូបលេខ៦៖ រូបសំណាកសត្វសេក

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ៧៖ កិច្ចបាញ់សេក (ផ្តាច់អមនុស្សឱ្យចេញពីមនុស្សបន្ទាប់ពីបញ្ចប់ពិធី)



រូបលេខ៨៖ កិច្ចបាញ់សេក (ផ្តាច់អមនុស្សឱ្យចេញពីមនុស្សបន្ទាប់ពីបញ្ចប់ពិធី)

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង